

ប្រភពធនធានចំរុះសំរាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
អាងភ្ញាស់ត្រី
កន្ទក់ ចុងអង្ករ
រុក្ខជាតិបៃតង
ចក
លាមកសត្វ
រណ្ដៅជីកំប៉ុស
កាកសំណល់បន្លែ
ម្ទេស
ប៉េងប៉ោះ
ត្រប់
ត្រី ស្រូវ

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

## មាតិកាអត្ថបទ


**សេចក្តីផ្តើម** ........ ៣

ផលប្រយោជន៍នៃការចិញ្ចឹមត្រី ........ ៤

ប្រភពធនធានសម្រាប់ចិញ្ចឹមត្រី ........ ៤

**I- បច្ចេកទេសចិញ្ចឹមត្រី** ........ ៥

១- លក្ខណៈស្រះ ........ ៥

ក- ការជ្រើសរើសទីតាំងជីកស្រះ ........ ៥

ខ- លក្ខណៈស្រះត្រី ........ ៥

គ- របៀបជីកស្រះ ........ ៦

២-ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម ........ ៨

ក-ការប្រើកំបោរ ........ ៨

ខ-ការប្រើជី ........ ៩

គ-ការរៀបចំស្រះ ........ ១១

៣- ការជ្រើសរើសប្រភេទកូនត្រីពូជដាក់ចិញ្ចឹម ........ ១១

ក- ប្រភេទត្រីជ្រើសរើសដាក់ចិញ្ចឹម ........ ១១

ខ- ចំនួនកូនត្រីដាក់ចិញ្ចឹម ........ ១៦

គ- ពេលវេលាដាក់កូនត្រីចិញ្ចឹម ........ ១៦

ឃ-ការដឹកជញ្ជូនកូនត្រី ........ ១៧

ង- ទំហំកូនត្រីត្រូវដាក់ចិញ្ចឹម ........ ១៨

ច- របៀបលែងកូនត្រី ........ ១៩

៤- ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម ........ ១៩
ក-ជីធម្មជាតិ ........ ២០
ខ-ជីគីមី ........ ២១
៥- ចំណី និងការផ្តល់ចំណី ........ ២១
ក-ប្រភេទចំណី ........ ២១
ខ-ការផ្តល់ចំណី ........ ២១
៦- ការគ្រប់គ្រងស្រះចិញ្ចឹមត្រី ........ ២៣
៧- ការប្រមូលផល ........ ២៥
ក-ការប្រមូលផលរំលោះ ........ ២៥
ខ-ការប្រមូលផលទាំងស្រុង ........ ២៦
II - ការកត់ត្រាចំណាយ និង ចំណូល ........ ២៧
III -កត្តាសំខាន់ៗដែលធ្វើឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ ... ២៨

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជាសំបូរធនធានមច្ឆជាតិ ដែលមាននៅក្នុងទន្លេ ស្ទឹង បឹងបួរ ព្រែក អូរ ប្រឡាយនានា។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ដោយសារមានការប្រែប្រួលបរិស្ថានធម្មជាតិ និងកំណើនប្រជាជនបានធ្វើឱ្យតម្រូវការត្រីកាន់តែកើនឡើងជាលំដាប់ ហើយបរិមាណផលត្រីក្នុងធម្មជាតិមិនអាចផ្គត់ផ្គង់បានតាមតម្រូវការ ។

ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាកសិករ នូវវិធីសាស្ត្រគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាពនៅតាមគ្រប់តំបន់ដែនទឹកធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយជួយរៀបចំបង្កើតឱ្យមានសហគមន៍គ្រប់គ្រងនៅតាមមូលដ្ឋាន ដើម្បីឱ្យប្រជាកសិករយល់ច្បាស់ពីតួនាទី និងភារៈកិច្ចក្នុងការគ្រប់គ្រងធនធានជលផលក្នុងតំបន់របស់ខ្លួន។ ក្រៅពីនេះរដ្ឋបាលជលផលសហការជាមួយគម្រោងនានា អនុវត្តការងារផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ក្នុងគោលបំណងដើម្បីធានាការផ្គត់ផ្គង់ម្ហូបអាហារ ទៅគ្រប់តំបន់ដែលប្រជាកសិករកំពុងទទួលការខ្វះខាតសាច់ត្រីទទួលទាន។ បច្ចុប្បន្ន មានប្រជាកសិករជាច្រើនគ្រួសារបានទទួលការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីពីមន្ត្រីជំនាញនៃរដ្ឋបាលជលផល សហការជាមួយបណ្ដាអង្គការនានា និងដោយមានការចូលរួមផ្សព្វផ្សាយពីកសិករផង ទាំងនេះបានធ្វើឱ្យពួកគាត់កំពុងមានសកម្មភាពចិញ្ចឹមត្រី និងឈានទៅផលិតកូនត្រីពូជនៅតាមតំបន់របស់ខ្លួនថែមទៀតផង។

ដើម្បីពង្រីកការងារផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្មនេះ រដ្ឋបាលជលផល បានរៀបចំចងក្រងសៀវភៅ **បច្ចេកទេសចិញ្ចឹមត្រី** នេះឡើងសំដៅជួយប្រជាកសិករនៅគ្រប់ទីកន្លែង ឱ្យចេះបច្ចេកទេសចិញ្ចឹមត្រី និងចូលរួមសកម្មភាពចិញ្ចឹមឱ្យបានផុសផុលទាំងអស់គ្នា ដើម្បីដោះស្រាយជីវភាពម្ហូបអាហារប្រចាំថ្ងៃ បង្កើនប្រាក់ចំណូល និង កាត់បន្ថយការចាប់ត្រីពីធម្មជាតិផង។

## ផលប្រយោជន៍នៃការចិញ្ចឹមត្រី

- បង្កើតបានជាមុខរបរក្រៅពីការធ្វើស្រែ-ចំការ
- កាត់បន្ថយការចំណាយថវិកាទិញត្រីពីផ្សារ
- តម្រូវការសាច់ត្រីបានទាន់ពេលវេលា និងជាម្ហូបប្រចាំថ្ងៃ
- ផ្តល់ប្រូតេអ៊ីន និងសារធាតុចិញ្ចឹមល្អដល់សុខភាពមនុស្ស
- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ
- កាត់បន្ថយការនេសាទត្រីពីធម្មជាតិ
- បង្កើនផលត្រីធម្មជាតិក្នុងតំបន់
- កាត់បន្ថយការងារនៅឆ្ងាយផ្ទះ ។

## ប្រភពធនធានសម្រាប់ចិញ្ចឹមត្រី

- មានចំណេះដឹងក្នុងការចិញ្ចឹមត្រី
- មានកំលាំងពលកម្មក្នុងការថែទាំស្រះចិញ្ចឹមត្រី
- ស្រះ និងទឹកមានលក្ខណៈសមស្រប ។ មានកូនត្រីពូជដាក់ចិញ្ចឹម
- មានកាកសំណល់កសិដ្ឋាន ឬ ប្រភពធនធានកសិដ្ឋានច្រើន ដូចជា ជីលាមកសត្វ និងកន្ទក់



ជីវភាពគ្រួសារមុនពេលចិញ្ចឹមត្រី

ជីវភាពគ្រួសារក្រោយពេលចិញ្ចឹមត្រី



## I- បច្ចេកទេសចិញ្ចឹមត្រី

### ១- លក្ខណៈស្រះ :

ស្រះតូចធំអាចចិញ្ចឹមត្រីបានទាំងអស់ តែស្រះមានទំហំធំល្មមទើបងាយស្រួលក្នុងការគ្រប់គ្រង និងចិញ្ចឹមត្រីមានប្រសិទ្ធភាពខ្ពស់។

#### ក. ការជ្រើសរើសទីតាំងជីកស្រះ

ស្រះគួរជីក ÷



- នៅជិតផ្ទះងាយស្រួលគ្រប់គ្រងបានគ្រប់ពេល
- ស្រះគួរជីកនៅកន្លែងទំនាប មិនលិចទឹកនៅរដូវវស្សា ឬលិចតិចតួច តែអាចលើកភ្លឺទប់បាន
- នៅទីកន្លែងដែលដីមានគុណភាពល្អ អាចរក្សាទឹកបានយូរ (លើសពី ៦ខែ)
- ស្ថិតនៅទីវាលស្រឡះ
- ជិតប្រភពទឹក (ប្រសិនបើមាន)
- ស្រះជាប់ស្រែកាន់តែប្រសើរ
- នៅឆ្ងាយពីតំបន់ ដែលមានការប្រើប្រាស់ថ្នាំពុលកសិកម្មផ្សេងៗ។

#### ខ. លក្ខណៈស្រះត្រី

ស្រះចិញ្ចឹមត្រីគួរ ÷

- ជីកមានរាងបួនជ្រុងទ្រវែង ដើម្បីងាយស្រួលគ្រប់គ្រង
- ស្រះមានទំហំប៉ុនណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានទំហំពី ១០០ ម៉ែត្រការ៉េឡើងទៅ
- ស្រះមានទំហំពី ១០០ ម៉ែត្រការ៉េឡើងទៅ សមស្របដល់ការចិញ្ចឹមត្រីបានធំធាត់

- ស្រះត្រូវមានជើងទេរ (ជំរាល) សមស្រប ដើម្បីការពារការហូរច្រោះ ឬ បាក់ដី
- ស្រះគួរមានជំរៅសមស្របពី ១.៥ម៉ែត្រ ទៅ ២.៥ម៉ែត្រ
- ស្រះត្រូវមានភ្លឺខ្ពស់ និងមាំល្អ ដើម្បការពារទឹកលិច
- ដាំស្មៅនៅតាមភ្លឺស្រះ ដើម្បីកាត់បន្ថយការហូរច្រោះដែលធ្វើឱ្យទឹកល្អក់
- បាតស្រះត្រូវរាបស្មើ ហើយមានជំរាលទៅជ្រុងម្ខាង ងាយស្រួលពង្រីង និងប្រមូលផល
- នៅតាមភ្លឺស្រះគួរបង្កប់បំពង់ សំរាប់បង្ហូរទឹកចូលស្រះ ។



## គ- របៀបជីកស្រះ

ឧទាហរណ៍ : បើជីកស្រះទំហំ ១៥ម X ១០ម X ២ម យើងត្រូវមានផ្ទៃដី ២១ម X ១៦ម ។ តំបូងត្រូវ :

- វាស់ចាប់ពីរបងផ្ទះ ឬក្បែររបងទុកយ៉ាងតិច ២ម ដើម្បីទុកធ្វើភ្លឺស្រះ
- ទុកយ៉ាងតិចប្រវែង ១ម ដើម្បីធ្វើចំណីភ្លឺ និងមាត់ស្រះ
- ចន្លោះពីមាត់ស្រះទៅជ្រុងនៃបាតស្រះមានប្រវែង ៦ម ជាចន្លោះសំរាប់ធ្វើជើងទេរស្រះ
- អាចម៍ដីជីកស្រះ ត្រូវយកមកធ្វើជាភ្លឺស្រះ ដោយបុកបង្ហាប់ឱ្យណែន
- យើងចាប់ផ្តើមវាស់ចេញពីគ្រប់ជ្រុងស្រះ (ទំហំ ១៥ម X ១០ម ) ប្រវែង 0.៧៥ម ជុំវិញ ហើយជីកជំរៅ 0.៥ម បានស្រទាប់កាំទី ១ ហើយដីស្រទាប់មុខលើជំរៅ ២តឹក ឬ 0.២ម ត្រូវជីកយកអាចម៍ដីនេះទុកម្តុំ ព្រោះជាដីមានជីជាតិ សំរាប់ក្រាលពីលើភ្លឺស្រះ ដាំស្មៅ ។



- រួចវាស់ចេញពីស្រទាប់កាំទីមួយប្រវែង 0.៧៥មទៀត និងជីកជំរៅ 0.៥ម ធ្វើយ៉ាងនេះរហូតបានចំនួនបួនស្រទាប់ សរុបជំរៅ ២ម និងមានបួនកាំនៅតាមជើងទេរស្រះ ។
- បាតស្រះជីកហើយមានទំហំ ៩ម X ៦ម និងមានជញ្ជាំងស្រះជំរាលល្អ ការពារការហូរច្រោះបាក់ដី



ស្រះចោតមិនល្អសម្រាប់ចិញ្ចឹមត្រី

ស្រះមានជើងទេរល្អសម្រាប់ចិញ្ចឹមត្រី



- បន្ទាប់ពីជីកចេញរាងស្រះហើយ យើងត្រូវយកស្រទាប់ដីខាងលើដែលយើងបានគរទុកមកចាក់នៅលើភ្លឺស្រះ ហើយបុកបង្ហាប់ និងចាប់ផ្តើមដាំស្មៅនៅតាមខ្នងភ្លឺ ជើងទេរភ្លឺ និងចំណើភ្លឺនៅមាត់ស្រះ ។
- នៅក្នុងភ្លឺស្រះត្រូវដាក់បង្កប់បំពង់បង្ហូរទឹកចូលស្រះឱ្យបានត្រឹមត្រូវ និងត្រូវការពារកុំឱ្យសត្វផ្សេងៗចូលទៅក្នុងស្រះ ។



ការដាំស្មៅនៅលើភ្លឺស្រះ

## ២ -ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម

**ក. ការប្រើកំបោរ** : ការប្រើប្រាស់កំបោរមានសារៈប្រយោជន៍ ដូចខាងក្រោម ÷



- សម្លាប់មេរោគ និង ពពួកសត្វមួយចំនួនដែលស៊ីត្រី
- ជួយកែលំអគុណភាពទឹក និងគុណភាពដីដែលមានជាតិជូរ ( អាស៊ីត)
- ធ្វើឱ្យកាកសំណល់ផ្សេងៗឆាប់រលួយ
- កាត់បន្ថយភាពល្អក់នៃទឹកស្រះ
- បន្ថែមសារជាតិចិញ្ចឹមដល់សត្វល្អិត និងរុក្ខជាតិប្លង់តុង ។

**បរិមាណកំបោរត្រូវប្រើប្រាស់ :**

តាមធម្មតាស្រះ ១០០ម៉ែត្រការ៉េ ប្រើកំបោរពី ៥ ទៅ១០គក្រ អាស្រ័យទៅនឹងភាពជាក់ស្តែងរបស់ទឹក និងដី ។ ប្រសិនបើស្រះមានជាតិអាស៊ីតខ្លាំង ឬ កាកសំណល់ផ្សេងៗច្រើន ក៏រិតកំបោរត្រូវប្រើអាចច្រើនជាងនេះបន្តិច ។

**វិធីសាស្ត្រក្នុងការប្រើកំបោរ :**

យើងត្រូវចាក់កំបោរចូលទៅក្នុងធុងដែកឱ្យបានកន្លះធុង បន្ទាប់មកចាក់ទឹកចូលធុង ។ ពេលចាក់ទឹកចូលធុងត្រូវប្រុងប្រយ័ត្ន ព្រោះកំបោរនៅពេលត្រូវទឹកវាចាប់ផ្តើមបញ្ចេញចំហាយក្តៅ ។ បន្ទាប់ពីកំបោរបញ្ចេញអស់ចំហាយក្តៅ យើងយកកំណាត់ឈើកូរទឹកកំបោរក្នុងធុងនោះ ហើយដួសបាចទៅក្នុងផ្ទៃស្រះ ។

### ការប្រុងប្រយ័ត្ន នៅពេលប្រើកំបោរស :

នៅពេលប្រើកំបោរដុំត្រូវតែប្រយ័ត្នប្រយែង ចៀសវាងការប៉ះពាល់ផ្ទាល់នូវចំហាយកំដៅកំបោរទៅ ស្បែក និងភ្នែក។ ប្រសិនបើមានចូលភ្នែកត្រូវលាងសំអាតវាជាមួយនឹងទឹកស្អាតឱ្យច្រើន ហើយពិគ្រោះយោបល់ជាមួយគ្រូពេទ្យ។

## ខ- ការប្រើជី :

ការប្រើជីមានន័យថា ការដាក់ជីទៅក្នុងស្រះត្រីនៅក្នុងពេលរៀបចំស្រះ។ ជាទូទៅជីលាមកសត្វ ឬ ជីគីមី ដូចជា ជីអ៊ុយរ៉េ និងដេអាប៉េ ផ្តល់សារជាតិចិញ្ចឹម (អាសូត និង ផូស្វ័រ) ទៅឱ្យរុក្ខជាតិ និងសត្វល្អិតប្លង់តុង ដែលជាចំណីធម្មជាតិសំខាន់សំរាប់ការលូតលាស់របស់ត្រី។

**ជីលាមកមាន់ :** វាមានសារធាតុអាសូត និង ផូស្វ័រច្រើនជាងជីលាមកសត្វផ្សេងៗទៀត។ ដូច្នេះលាមកមាន់ជាជីល្អសំរាប់ការចិញ្ចឹមត្រី។ ក្នុងពេលរៀបចំស្រះយើងអាចដាក់វាផ្ទាល់ចូលទៅក្នុងស្រះចំនួន ១០គក្រ/១០០ម$^{២}$ ទឹកស្រះ។

**ជីលាមកជ្រូក :** វាមានសារធាតុផូស្វ័រច្រើនប្រហែលគ្នានឹងជីលាមកមាន់ដែរ។ ការចិញ្ចឹមជ្រូកដាក់ទ្រុងនៅក្បែរស្រះចិញ្ចឹមត្រី ហើយបង្ហូរកាកសំណល់លាមកជ្រូកចូលទៅក្នុងស្រះត្រី ជាវិធីមួយដ៏ល្អដែលត្រូវបានអ្នកចិញ្ចឹមត្រីជាច្រើនប្រទេសលើពិភពលោកកំពុងអនុវត្ត។ ប៉ុន្តែគួរជីករណ្តៅនៅក្បែរទ្រុងជ្រូកភ្ជាប់ទៅនឹងស្រះត្រី ដើម្បីឱ្យលាមកជ្រូក និងទឹកដែលយើងលាងជ្រូកចូលទៅក្នុងរណ្តៅសិន មុននឹងបង្ហូរទឹកលាមកជ្រូកនោះចូលស្រះ។ បើពុំមានចិញ្ចឹមជ្រូកដាក់ទ្រុងទេ យើងត្រូវប្រមូលលាមកជ្រូកមកដាក់ក្នុងរណ្តៅជី រួចចាក់ទឹកត្រាំឱ្យបាន ១ អាទិត្យ ទើបបង្ហូរចូលស្រះ។

**ជីលាមកគោ ក្របី :** វាមានសារធាតុអាសូត និងផូស្វ័រទាបជាងជីលាមកសត្វផ្សេងៗទៀត តែវាអាចរកបានច្រើននៅតាមជនបទ។ ក្នុងស្រះចិញ្ចឹមត្រី ១០០ម$^{២}$ យើងអាចប្រើលាមកគោ ក្របីសើមចំនួន ១០០គក្រ ឬ លាមកគោ ក្របីស្ងួត ៥០គក្រ ហើយមិនគួរយកវាទៅដាក់ផ្ទាល់ក្នុងស្រះទេ ត្រូវដាក់វាក្នុងរណ្តៅនៅក្បែរស្រះត្រី ដើម្បីបង្ហូរជាតិទឹកជីនោះចូលទៅក្នុងស្រះទើបវាល្អប្រសើរជាង។

**ជីកំប៉ុស :** ជាជីដែលបានមកពីការរួមផ្សំរវាងកាកសំណល់រុក្ខជាតិ បន្លែ លាមកសត្វ ចំប៉ើង និងដី ដើម្បីបំបែកធាតុក្លាយជាជីដ៏ល្អសំរាប់ដំណាំ។ វាអាចប្រើសម្រាប់ការចិញ្ចឹមត្រីបាន ដោយដាក់វាក្នុងរណ្តៅជីលាមកសត្វ រួចសឹមបង្ហូរចូលស្រះ។

ជីបែតង : នៅពេលដែលយើងយកស្លឹករុក្ខជាតិ និងមែកមកប្រើជាជី យើងហៅថាជីបៃតង។ កសិករគួរតែកត់សំគាល់ថា ប្រសិទ្ធភាពរបស់ជីបៃតងកើតមាននៅក្រោយពេលមែកធាង និងស្លឹករុក្ខជាតិរលួយ។ ប្រសិនបើយើងយកជីបៃតងទៅប្រើក្នុងស្រះត្រីបានពី ២ ទៅ ៣ថ្ងៃ វាចាប់ផ្តើមរលួយហើយស្រូបយកខ្យល់អុកស៊ីសែនដែលមានក្នុងស្រះត្រី រួចបញ្ចេញជាឧស្ម័នកាបូនិច (ខ្យល់ពុល) ដែលធ្វើឱ្យទឹកស្រះក្លាយទៅជាជាតិអាស៊ីត។ ដូច្នេះកសិករមិនគួរប្រើជីនេះផ្ទាល់ទៅក្នុងស្រះចិញ្ចឹមត្រីទេ។ ជីបៃតងត្រូវតែដាក់វាឱ្យរលួយជាមួយរណ្តៅជីលាមកសត្វសិន សឹមបង្ហូរទឹកជីចូលស្រះ។

## បរិមាណជី និងកំបោរដែលត្រូវប្រើ ក្នុងពេលរៀបចំស្រះត្រី

| បរិយាយ | ស្រះចាស់ (១០០ម²) | ស្រះថ្មី (១០០ម²) |
|---|---|---|
| កំបោរ | ៥-១០ គក្រ | ១០ ទៅ ១៥គក្រ |
| លាមកគោ ឬ ក្របីសើម | ៦០ ទៅ ៨០គក្រ | ៨០ ទៅ ១០០គក្រ |
| លាមកជ្រូកសើម | ២០ ទៅ ៣៥គក្រ | ២៥ ទៅ ៤០គក្រ |
| លាមកមាន់-ទាសើម | ១០ ទៅ ១៥គក្រ | ១៥ ទៅ ២០គក្រ |
| ស្លឹកទន្រ្ទានខែត្រ | ២០ទៅ ៣០គក្រ | ៣០ ទៅ ៤០គក្រ |
| ដេ អា ប៉េ | ៣ ខាំ | ១ គ.ក្រ |
| អ៊ុយរ៉េ | ៧ ខាំ | ២ គ.ក្រ |

**បញ្ជាក់ :** ជីគីមី ត្រូវលាយទឹកឱ្យរលាយ ហើយបាចទឹកជីទៅក្នុងស្រះ

សរុបសេចក្តីមក ដើម្បីឱ្យស្រះចិញ្ចឹមត្រីសម្បូរចំណីធម្មជាតិ យើងមិនត្រូវប្រើជីទាំងអស់ខាងលើដាក់ចូលក្នុងស្រះផ្ទាល់ទេ ទោះបីជាជីនោះមានបរិមាណតិចតួចក៏ដោយ ព្រោះវានឹងបង្កើតជាតិស្អុយបន្តិចម្តងៗនៅបាតស្រះ។ ដូចនេះការដាក់ជីទៅក្នុងរណ្តៅហើយបង្ហូរទឹកជីទៅក្នុងស្រះ ជាទង្វើដ៏ល្អប្រសើរសំរាប់ស្រះចិញ្ចឹមត្រី។

### គ. ការរៀបចំស្រះ :

**ការរៀបចំស្រះត្រូវធ្វើតាមលំដាប់ដូចខាងក្រោម ÷**

- ត្រូវបូមពង្រីងស្រះ ដើម្បីចាប់ត្រីស្រែ កង្កែប អន្ទង់ ក្តាម...
- ត្រូវស្តារភក់បាតស្រះ ទុកជំរៅមិនលើសពី ១,៥តឹក
- កែលំអស្រះឡើងវិញដូចជា លុបរន្ធក្តាម និងជួសជុលភ្លឺស្រះ
- ត្រូវប្រើកំបោរក្រោយពេលបូមទឹកស្រះពង្រីង ឬ ប្រើកំបោរមុនពេលបញ្ចូលទឹក ( ចំពោះស្រះថ្មី )
- ត្រូវហាលស្រះឱ្យបានពី ១ ទៅ ២ថ្ងៃ
- រួចបញ្ចូលទឹកទៅក្នុងស្រះឱ្យបាន ១ ភាគ៣ នៃជំរៅស្រះ ទន្ទឹមនឹងនោះត្រូវបង្ហូរទឹកជីពីរណ្តៅជីចូលក្នុងស្រះ ឬ បន្ថែមជីរុក្ខជាតិបៃតងដាក់ត្រង់កាច់ជ្រុងស្រះ
- បន្ទាប់មកត្រូវបញ្ចូលទឹកបន្ថែមទៅក្នុងស្រះឱ្យពេញ ទុករយៈពេល ២ ទៅ ៣ថ្ងៃ ឬ នៅពេលទឹកស្រះប្រែពណ៌បៃតងខ្ចី ទើបអាចលែងកូនត្រីចូលក្នុងស្រះបាន។



សកម្មភាពចាប់ត្រីកាច

## ៣- ការជ្រើសរើសប្រភេទកូនត្រីពូជដាក់ចិញ្ចឹម

### ក- ប្រភេទត្រីដាក់ចិញ្ចឹម

គួរជ្រើសរើសប្រភេទត្រីទាំងឡាយណាដែលមានលក្ខណៈដូចខាងក្រោមនេះ :-

- ងាយចិញ្ចឹមក្នុងស្រះ និងក្នុងស្រែ
- ងាយរកពូជមកចិញ្ចឹម
- ធន់នឹងជំងឺ

- ស៊ីចំណីធម្មជាតិ និងចំណីបន្ថែមដែលអាចរកបាន
- មានតម្លៃក្នុងទីផ្សារ ឬ ប្រជាជននិយមចូលចិត្តបរិភោគ
- ចំពោះប្រភេទត្រីទាំងនោះ មានដូចជា ត្រីឆ្ពិន កន្ធរ ក្រាញ់ ប្រា ព្រលូង ត្រីទីឡាព្យ៉ា កាបស កាបក្បាលធំ កាបសាមញ្ញ កាបឥណ្ឌា... ។ល។

## ១. ត្រីឆ្ពិន

ជាប្រភេទត្រីក្នុងស្រុក រស់នៅតាមទន្លេ ស្ទឹង បឹង បួរ

- ពេលនៅតូច វាស៊ីសត្វល្អិតតូចៗច្រើនប្រភេទដូចជា ក្រុមស្លឹករុក្ខជាតិជាសារាយតូចៗ ពពួកសត្វប្លង់តុង និងសត្វល្អិតតូចៗផ្សេងទៀតដូចជា កណ្ដៀរ ... ។
- ពេលធំវាស៊ីចំណី ដូចជា កាកសំណល់បន្លែ, ស្លឹករុក្ខជាតិ, ចក, ត្រកួន ជាដើម
- អាចស៊ីចំណីបន្ថែមដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយ ជាដើម
- ចូលចិត្តរស់នៅស្រទាប់លើ និងកណ្ដាល
- អាចមានទំងន់ពី ២- ៥ ខាំ រយៈពេលចិញ្ចឹមក្នុងស្រះ ១ឆ្នាំ បើមានការគ្រប់គ្រងល្អ
- ត្រីឆ្ពិនអាចបន្តពូជបាននៅអាយុ ៨ខែ ឡើងទៅ
- ធន់នឹងជំងឺ ។



ត្រីឆ្ពិន

## ២. ត្រីកន្ធរ

ជាប្រភេទត្រីក្នុងស្រុក មានតម្លៃសេដ្ឋកិច្ចខ្ពស់ រស់នៅក្នុងទឹកនឹង ដូចជា បឹង ត្រពាំង ថ្លុក ស្រែ និង ប្រឡាយ ។

- ចូលចិត្តស៊ីចំណីច្រើនប្រភេទ ដូចជា បន្លែ, ស្លឹករុក្ខជាតិ, ចក, ត្រកួន, កណ្ដៀរ ... ។ល។ តែចំណីសំខាន់ គឺប្លង់តុង

- ចូលចិត្តរស់នៅស្រទាប់លើ និងកណ្ដាល
- អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយ ជាដើម
- អាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានជាតិជូរតិច (ប៉េហាស់ សមស្រប ពី ៥,៦ ទៅ ៦)
- អាចរស់នៅក្នុងមជ្ឈដ្ឋានទឹក ដែលមានកំរិតអុកស៊ីសែនទាប
- មានទំងន់ ០,៥- ១ ខាំ រយះពេល ១ ឆ្នាំ ក្នុងស្រះចិញ្ចឹម
- ត្រីអាចបន្តពូជបាននៅក្នុងស្រះ ពេលមានអាយុលើសពី ៧ ខែ
- ធន់នឹងជំងឺ ។



ត្រីកន្ធរ

## ៣. ត្រីកាប ស

ជាប្រភេទត្រីក្រៅស្រុក មានប្រភពមកពីប្រទេសចិន រស់នៅក្នុងតំបន់ទឹកសាប ។ ជាត្រីដែលងាយស្រួលចិញ្ចឹម រស់នៅក្នុងមជ្ឈដ្ឋានទឹកមានគុណភាពល្អ

- ស៊ីចំណីសត្វល្អិតប្លង់តុង ពេលត្រីនៅតូច និងស៊ីរុក្ខជាតិប្លង់តុង នៅពេលវាធំ
- អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយ ជាដើម
- រស់នៅស្រទាប់លើ និងកណ្ដាល
- អាចរស់នៅក្នុងមជ្ឈដ្ឋានទឹក (ប៉េហាស់ សមស្រប ពី ៦,៥ ទៅ ៨) សីតុណ្ហភាព ២០-៣០ អង្សាសេ
- លូតលាស់ល្អ អាចមានទំងន់ពី ៥ ទៅ ៧ ខាំ ក្នុងរយះពេល ១ឆ្នាំ
- ពេញវ័យនៅពេលវាមានអាយុពី ១ ទៅ ២ ឆ្នាំ
- មិនអាចបន្តពូជក្នុងស្រះបានទេ ។



ត្រីកាបស

## ៤. ត្រីទីឡាព្យ៉ា (ទីឡាព្យ៉ាឆ្នូតបញ្ឈរ)

ជាប្រភេទត្រីក្រៅស្រុក មានប្រភពមកពីប្រទេសអាព្រិចខាងជើង។ រស់នៅក្នុងតំបន់ទឹកសាប និងអាចរស់នៅក្នុងទឹកភ្លាវ។ ជាត្រីងាយស្រួលចិញ្ចឹម ព្រោះវាអាចធន់នឹងមជ្ឈដ្ឋានរស់នៅ ដែលមានកំរិតបរិមាណខ្យល់អុកស៊ីសែនរលាយក្នុងទឹកទាប។

- ស៊ីចំណីចំរុះ (រុក្ខជាតិក្នុងទឹក, ស្លែ, ជន្លេន, កណ្ដៀរ) អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម
- រស់នៅគ្រប់ស្រទាប់ទឹក
- អាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានជាតិជូរតិច (ប៉េហាស់ល្អ ពី ៤ ទៅ ៩) សីតុណ្ហភាព ១៤-៤០ អង្សាសេ
- លូតលាស់ល្អអាចមានទំងន់ពី ២ ខាំ ទៅ ៥ ខាំ ក្នុងរយៈពេលចិញ្ចឹម ៨ ខែ
- ពេញវ័យនៅពេលវាមានអាយុ ៤ ខែ ឡើងទៅ
- ងាយពង និងញាស់កូននៅក្នុងស្រះ ដោយធម្មជាតិ
- ធន់នឹងជំងឺ ។



ត្រីទីឡាព្យ៉ា

## ៥. ត្រីកាបសាមញ្ញ

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប ជាប្រភេទត្រីដែលងាយស្រួលចិញ្ចឹម ព្រោះវាអាចធន់នឹងមជ្ឈដ្ឋានរស់នៅដែលមានកំរិតបរិមាណអុកស៊ីសែន រលាយក្នុងទឹកទាប ។

- ស៊ីចំណីចំរុះ (កូនខ្យង ខ្ចៅ ក្ដាម ជន្លេន កណ្ដៀរ សត្វល្អិត រុក្ខជាតិក្នុងទឹក ....)
- អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្ដែក កាកសំណល់ផ្ទះបាយជាដើម
- រស់នៅស្រទាប់បាត



ត្រីកាបសាមញ្ញ

- អាចរស់នៅក្នុងមជ្ឍដ្ឋានទឹកដែលមានប៉េហាស់ពី ៥.៥  ទៅ ៨.៥  និងសីតុណ្ហភាព២០-៣០ អង្សាសេ
- លូតលាស់ល្អអាចពី ០.៥ ទៅ ១ គ.ក្រ ក្នុងរយៈពេល ១ឆ្នាំ
- ពេញវ័យនៅពេលវាមានអាយុ ៨ ខែ ឡើងទៅ
- អាចបន្តពូជបាននៅក្នុងស្រះ
- ធន់នឹងជំងឺ ។

## ៦. ត្រីកាបឥណ្ឌា " ម្រឹហ្គាល់ "



ត្រីកាបឥណ្ឌា

ជាប្រភេទត្រីក្រៅស្រុក រស់នៅក្នុងតំបន់ទឹកសាប  ជាប្រភេទត្រីដែលងាយស្រួលចិញ្ចឹម ។

- ស៊ីចំណីចំរុះ ( សត្វល្អិតក្នុងទឹក រុក្ខជាតិក្នុងទឹក ចកបាយទា ....)
- អាចស៊ីចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ ពោត សណ្តែក កាកសំណល់ផ្ទះបាយ ជាដើម
- រស់នៅស្រទាប់បាត
- អាចរស់នៅក្នុងមជ្ឍដ្ឋានទឹក ដែលមានប៉េហាស់ពី ៥.៥  ទៅ ៨.៥   និង សីតុណ្ហភាព ២០-៣០ អង្សាសេ
- លូតលាស់ល្អអាចពី ០.៥ ទៅ ០.៧ គ.ក្រ ក្នុងរយៈពេល ១ ឆ្នាំ
- ពេញវ័យនៅពេលវាមានអាយុ ១.៥ ឆ្នាំ ឡើងទៅ
- ធន់នឹងជំងឺ ។

## ខ. ចំនួនកូនត្រីដាក់ចិញ្ចឹម

- គួរដាក់កូនត្រីចិញ្ចឹមពី ៣ ទៅ ៤ ក្បាល ក្នុង ១ម៉ែត្រការ៉េ ឬ ពី ៣០០ ទៅ ៤០០ ក្បាល ក្នុង ១០០ម៉ែត្រការ៉េ
- គួរដាក់កូនត្រីចិញ្ចឹមចំរុះចាប់ពី ៣ប្រភេទ ឡើងទៅ ដើម្បីប្រើប្រាស់ចំណីអស់ពីក្នុងស្រះ
- ប្រភេទត្រីត្រូវដាក់ចិញ្ចឹមតាមភាគរយ មានដូចខាងក្រោមនេះ÷

| ប្រភេទត្រី | ឆ្ពិន | ទីឡាព្យ៉ា | កាបស | កាបសាមញ្ញ/ឥណ្ឌា |
|---|---|---|---|---|
| ប្រភេទត្រីឆ្ពិន ជាសំខាន់ | ៤០ % | ៣០ % | ២០ % | ១០ % |
| ប្រភេទត្រីទីឡាព្យ៉ា ជាសំខាន់ | ៣០ % | ៤០ % | ២០ % | ១០ % |
| ក្នុងករណីចិញ្ចឹមតែ ៣ ប្រភេទ | | ៥០ % | ៤០ % | ១០ % |




## គ. ពេលវេលាដាក់កូនត្រីចិញ្ចឹម

ជាទូទៅ យើងអាចចិញ្ចឹមត្រីបានគ្រប់ពេលវេលា អាស្រ័យទៅនឹងស្រះមានទឹកគ្រប់គ្រាន់។ ប៉ុន្តែចំពោះស្រះដែលពឹងផ្អែកទៅលើប្រភពទឹកភ្លៀង ត្រូវដាក់ទៅពេលស្រះមានទឹកគ្រប់គ្រាន់ ដើម្បីឱ្យកូនត្រីចិញ្ចឹមបានរយៈពេលយូរ និងមានការលូតលាស់ធំធាត់បានល្អ។

## ឃ. ការដឹកជញ្ជូនកូនត្រី

ការដឹកជញ្ជូនកូនត្រីមាន ២របៀប គឺ ការដឹកជញ្ជូនដោយបិទជិត និងការដឹកជញ្ជូនដោយចំហ។

❑ ការដឹកជញ្ជូនដោយបិទជិត : គឺជាការដឹកជញ្ជូនកូនត្រីដោយប្រើថង់ប្លាស្ទិក និងខ្យល់អុកស៊ីសែន សម្រាប់ដឹកជញ្ជូនផ្លូវឆ្ងាយ ឬដឹកជញ្ជូនផ្លូវជិតក៏បាន។ ការដឹកជញ្ជូននេះត្រូវមានសំភារៈ ដូចជា ថង់ប្លាស្ទិក កៅស៊ូចងថង់ កញ្ចេ សម្រាប់ដាក់ថង់កូនត្រី ខ្សែចង និង ខ្យល់អុកស៊ីសែន។ ឧទាហរណ៍ ថង់ប្លាស្ទិក ដែលមានទំហំ ៦០ ស.ម X ១០០ ស.ម អាចដាក់កូនត្រីបានចំនួនពី ៣០០ ទៅ ៥០០ ក្បាល បើកូនត្រី មានទំហំ ៣- ៥ ស.ម។ ដើម្បីដឹកជញ្ជូនកូនត្រីឱ្យបានល្អ ចៀសវាងការធ្លាយថង់ក្នុងពេលដឹកជញ្ជូន គួរប្រើថង់ដាក់កូនត្រី ២ ជាន់ និងត្រូវចងគូទថង់ថែមទៀត ។



ការដឹកជញ្ជូនកូនត្រីផ្លូវឆ្ងាយ ត្រូវប្រើថង់ប្លាស្ទិក និងត្រូវបំពេញដោយខ្យល់អុកស៊ីសែន

❑ **ការដឹកជញ្ជូនដោយចំហ** : គឺជាការដឹកជញ្ជូនកូនត្រីប្រើសម្រាប់ផ្លូវជិត អាចប្រើសំភារៈ ដូចជា ធុង ប៉ោត ជាដើម ។ល ។



**របៀបដឹកជញ្ជូនកូនត្រីក្នុងចម្ងាយផ្លូវជិតៗ ដោយប្រើធុង ឆ្នាំង ឬ សម្ភារៈស្អាតល្អផ្សេងៗទៀត**

យើងត្រូវជ្រើសរើសយករបៀបដឹកជញ្ជូនណាមួយ ដោយយោងទៅតាមសភាពជាក់ស្តែងនៃចំងាយផ្លូវក្នុងពេលដឹកជញ្ជូន ។ ការដឹកជញ្ជូនកូនត្រីគួរធ្វើនៅពេលព្រឹក ពេលមានអាកាសធាតុត្រជាក់ ។ ចំនួនកូនត្រីដែលត្រូវដឹកជញ្ជូន គឺអាស្រ័យ ទៅនឹងទំហំកូនត្រី ចំងាយផ្លូវ និង រយៈពេលដឹកជញ្ជូន ។

## ង. ទំហំកូនត្រីត្រូវដាក់ចិញ្ចឹម

ដើម្បីទទួលបានផលពីការចិញ្ចឹមត្រី កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ និងមានទំហំធំប្រវែងពី ៥- ៦ ស.ម ឬ ៣ ថ្នាំងដៃ ដើម្បីឱ្យកូនត្រីគេចផុតពីសត្រូវ ដែលធ្វើឱ្យកូនត្រីមានអត្រារស់ច្រើន ។ ម្យ៉ាងទៀត ការដាក់កូនត្រីចិញ្ចឹមមានទំហំធំ ធ្វើឱ្យការលូតលាស់កូនត្រីបានធាត់ធំឆាប់រហ័ស ។



### ច- របៀបលែងកូនត្រី

- ពេលវេលាសមស្របសំរាប់លែងកូនត្រី ត្រូវធ្វើនៅពេលអាកាសធាតុត្រជាក់ ពិសេសចាប់ពីម៉ោង ៨ ទៅ ១១ ព្រឹក
- ករណីទឹកស្រះក្តៅខ្លាំង យើងត្រូវយកដៃកូរទឹក ពីក្រោមមកលើដើម្បីឱ្យទឹកស្រះមានកំដៅប្រហាក់ប្រហែលគ្នា
- មុនពេលលែងត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះរយៈពេល ១០-១៥ នាទី ដើម្បីឱ្យសីតុណ្ហភាពទឹកក្នុងថង់កូនត្រី មានកំដៅប្រហាក់ប្រហែលគ្នា នឹងទឹកស្រះ
- ស្រាយមាត់ថង់រួចយកដៃបាចទឹកស្រះបញ្ចូលថង់ បន្ទាប់មកផ្អៀងថង់ ដើម្បីឱ្យកូនត្រីហែលចេញតាមសម្រួល ។




## ៩- ការដាក់ជីបន្ថែមក្រោយពេលដាក់ត្រីចិញ្ចឹម

ក្រោយពីដាក់កូនត្រីចិញ្ចឹមរយៈពេលពី ១០ ទៅ ១៥ថ្ងៃ យើងត្រូវពិនិត្យមើលទឹកស្រះ (ឬមើលចំណីធម្មជាតិក្នុងស្រះ) បើឃើញទឹកស្រះមានពណ៌បៃតងចាស់ មានន័យថាក្នុងស្រះមានចំណីធម្មជាតិបួង់គុង តែបើទឹកស្រះលែងមានពណ៌បៃតង ត្រូវបន្ថែមជីតាមវិធីសាស្ត្រ ដូចខាងក្រោម :-

## ក- ជីធម្មជាតិ

- ជីករណ្ដៅនៅក្បែរស្រះទំហំ ១ទៅ ១.៥ម៉ែត្របួនជ្រុង ឬជីកមានរាងជាបួនជ្រុងទ្រវែងក៏បាន ជំរៅ ៥តឹក និងមានចង្អូរ ឬបំពង់សម្រាប់បង្ហូរទឹកជីចូលស្រះ។ ហើយបាតរណ្ដៅ ត្រូវឱ្យខ្ពស់ជាងផ្ទៃទឹកស្រះ ដើម្បីងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រះ។ ទឹកជីក្នុងរណ្ដៅត្រូវបង្ហូរចូលស្រះ នៅពេលថ្ងៃ។
- ក្នុងរណ្ដៅត្រូវដាក់ជីកំប៉ុស ឬ ជីលាមកសត្វគោ ក្របី ជ្រូក មាន់ ទា និង ជីរុក្ខជាតិបៃតងមានដូចជា ដើមទន្ទ្រានខែត្រ កាកសំណល់បន្លែងាយរលួយ និង ត្រូវចាក់ទឹកក្នុងរណ្ដៅត្រាំជីរៀងរាល់ថ្ងៃ ដើម្បីឱ្យជីឆាប់រលួយ រួចបង្ហូរទឹកជីចូលស្រះ។
- កាកសំណល់ជីក្នុងរណ្ដៅត្រូវប្ដូរសារជាថ្មីក្នុងរយៈពេលពី ២០ ទៅ ៣០ថ្ងៃ
- ក្នុងករណីទឹកស្រះមានពណ៌បៃតងចាស់ ឬពណ៌ត្នោត ឬទឹកមានធំក្លិនស្អុយ ត្រូវបញ្ឈប់ការបង្ហូរទឹកជីចូលស្រះមួយរយៈ។






### ខ- ជីគីមី

ជីគីមីក៏មានសារៈសំខាន់សំរាប់បង្កើតប្លង់តុង។ បរិមាណជីគីមីសម្រាប់ប្រើដាក់ស្រះចិញ្ចឹមត្រីគឺ ជីដេអាប៉េចំនួន ៣ខាំ និងជីអ៊ុយរ៉េ ៧ខាំ កូរលាយជាមួយទឹកឱ្យរលាយគ្រាប់អស់សិន ទើបយកទៅបាចឱ្យសព្វលើផ្ទៃទឹកស្រះទំហំ ១០០ ម៉ែត្រការ៉េ ។ ក្នុងកំឡុងពេលពី ២ទៅ ៥ថ្ងៃក្រោយមកទឹកស្រះនឹងប្រែពណ៌បៃតង។ ត្រូវឧស្សាហ៍បន្ថែមជីតាមបរិមាណខាងលើរៀងរាល់សប្តាហ៍ ដើម្បីរក្សាទឹកស្រះឱ្យមានពណ៌បៃតងជានិច្ច។ ក្នុងករណីទឹកស្រះមានពណ៌បៃតងចាស់ ត្រូវបញ្ឈប់ការដាក់ជីមួយរយៈសិន។

## ៥- ចំណី និងការផ្តល់ចំណី

### ក- ប្រភេទចំណី

ចំណីមានសារៈសំខាន់ណាស់សំរាប់ការលូតលាស់របស់ត្រី។ ចំណីមាន ២ប្រភេទ គឺ ចំណីធម្មជាតិ និងចំណីបន្ថែម។

**ចំណីធម្មជាតិ** : រួមមានសត្វប្លង់តុង រុក្ខជាតិប្លង់តុង និងសត្វស្រទាប់បាតមានដូចជា ខ្ចៅ ខ្យង ជន្លេនក្រហមជាដើម។

**ចំណីបន្ថែម** : បានមកពីការផ្សំប្រភេទចំណីមួយចំនួនដូចជា: កន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្តែក ឬ ចំណីគ្រាប់ ជាដើម។ ក្រៅពីនេះ ចំណីដែលអាចរកបាននៅក្នុងភូមិមាន ចកបាយទា ពងទឹក កណ្តៀរ ជន្លេន កាកសំណល់ផ្ទះបាយ បន្លែ និង កាកសំណល់ទីសត្តឃាដ ។ល។ ក៏ជាចំណីបន្ថែមសម្រាប់ ត្រីផងដែរ។

### ខ. ការផ្តល់ចំណី

ការលូតលាស់របស់ត្រី គឺអាស្រ័យដោយគុណភាព និងបរិមាណចំណីដែលផ្តល់ឱ្យត្រី

- ការផ្តល់ចំណីត្រីត្រូវកំណត់ទីកន្លែងដាក់ចំណី និងទៀងទាត់ពេលវេលា
- ចំណីត្រូវផ្តល់នៅពេលព្រឹកចន្លោះពីម៉ោង ៩ ទៅ ១០ និងពេលរសៀលចន្លោះពីម៉ោង ៤ ទៅ៥



- បរិមាណចំណីដែលផ្ដល់ឱ្យត្រីស៊ីត្រូវប្រែប្រួលទៅតាមទំហំរបស់ត្រីគឺ ពី ៣ ទៅ ៥ភាគរយនៃទំងន់ត្រីសរុបក្នុងស្រះ
- ចំណីដែលផ្សំឡើងពី (កន្ទក់ ម្សៅត្រី ចុងអង្ករ ពោត សណ្ដែក...) មុននឹងដាក់ឱ្យត្រីស៊ីត្រូវចំអិនឱ្យឆ្អិនទុកឱ្យត្រជាក់ រួចពូតជាដុំដាក់ក្នុងកញ្ជ្រែង ហើយពន្លិចក្នុងទឹកជំរៅពី ៣តឹក ទៅ ៥តឹក ។
- ចំពោះចំណីអណ្ដែតដូចជា ចកបាយទា ពងទឹក កាកសំណល់បន្លែ...ត្រូវធ្វើស៊ុមដាក់នៅកាច់ជ្រុងស្រះ
- នៅពេលផ្ដល់ចំណីត្រីត្រូវត្រួតពិនិត្យមើលត្រីស៊ីចំណីដាក់ស្ដែងនៅក្នុងកញ្ជ្រែងចំណី ក្រោយពីដាក់រយៈពេល ១ ម៉ោង ចៀសវាងផ្ដល់ចំណីច្រើនពេកត្រីស៊ីមិនអស់ នាំឱ្យខូចគុណភាពទឹក ។

ជាទូទៅកសិករភាគច្រើន តែងតែផ្ដល់កន្ទក់ឱ្យត្រីស៊ី ។ តាមបទពិសោធន៍ដែលបានស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការផ្ដល់ចំណីកន្ទក់ម៉ត់អស់ ៥គក្រ ទទួលផលត្រីបាន ១គក្រ។ ដូច្នេះគួរចៀសវាងការផ្ដល់ចំណីកន្ទក់សុទ្ធ ដោយការបាចទៅលើផ្ទៃស្រះ នាំឱ្យខាតបង់ គួរយកកន្ទក់ចំអិនជាមួយម្សៅត្រី និងចុងអង្ករ ឱ្យឆ្អិន រួចទុកឱ្យត្រជាក់ ទើបដាក់ឱ្យត្រីស៊ីជាការប្រសើរ ។




ការដាក់ចំណីឱ្យត្រីដោយប្រើកញ្ជ្រែង



## ៦- ការគ្រប់គ្រងស្រះចិញ្ចឹមត្រី

ដើម្បីឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ  យើងត្រូវយកចិត្តទុកដាក់លើកត្តាមួយចំនួនបន្ថែមទៀត ដូចជា :-

- សំអាតស្មៅ ដែលដុះតាមខាងៗស្រះ
- សំអាតរុក្ខជាតិទឹកដែលមិនចាំបាច់ចេញពីស្រះត្រី  (សូមមើលរូបភាពខាងក្រោម)
- ត្រួតពិនិត្យភ្លឺស្រះក្រែងមានធ្លុះធ្លាយ បាក់ស្រុត...ដើម្បីចៀសវាងការល្អក់ទឹក
- ពិនិត្យគុណភាពទឹកស្រះ  ធ្វើឱ្យមានពណ៌បៃតងជានិច្ច







- ពិនិត្យ និងកំចាត់សត្វដែលបំផ្លាញត្រីក្នុងស្រះមានដូចជា ពស់ កង្កែប សត្វក្រចាត... ។ល។
- មិនត្រូវឱ្យគោ  ក្របី  ជ្រូក ឬ សកម្មភាពផ្សេងៗដែលធ្វើឱ្យល្អក់ទឹកស្រះ
- មិនត្រូវប្រើប្រាស់សារជាតិពុលផ្សេងៗដូចជា  ថ្នាំសម្លាប់សត្វល្អិតចង្រៃ ឬម្សៅសាប៊ូ  នៅក្នុង  និងជុំវិញស្រះ (សូមមើលរូបភាពខាងក្រោម)
- មិនត្រូវឱ្យកាកសំណល់ផ្សេងៗ  ដូចជាត្រឡោកដូង សំបកផ្លែឈើ និងរុក្ខជាតិចូលក្នុងស្រះ
- មិនត្រូវត្រាំស្លឹកត្នោត  ឈើ  ឬស្សី  ឬរុក្ខជាតិផ្សេងៗ ដែលធ្វើឱ្យទឹកស្រះចិញ្ចឹមត្រីមានជាតិពុល  (សូមមើលរូបភាពខាងក្រោម)



ហាមបោកគក់ខោ អាវ ក្នុងស្រះចិញ្ចឹមត្រី



ហាមត្រាំស្លឹកត្នោត ឬ ស្លឹកឈើក្នុងស្រះចិញ្ចឹមត្រី



ហាមលាងសំភារៈថ្នាំពុលក្នុងស្រះចិញ្ចឹមត្រី

- បើឃើញត្រីមានជំងឺ ឬសត្វងាប់ ត្រូវស្រង់យកចេញជាបន្ទាន់
- នៅពេលព្រឹកព្រលឹម ប្រសិនបើឃើញត្រីងើបច្រើន មានសកម្មភាពហែលខុសពីធម្មតា ( មិនធ្មើល) នោះបញ្ជាក់ថា ត្រីខ្វះខ្យល់ដកដង្ហើម ឬត្រីពុល។ ជួបប្រទះករណីដូចនេះ ត្រូវធ្វើទឹកស្រះឱ្យមានចលនា ឬ បូមទឹកថ្មីមានគុណភាពល្អ បន្ថែមបញ្ចូលទៅក្នុងស្រះ និងត្រូវផ្អាកការផ្តល់ចំណី និងជីមួយរយៈពេលសិន។



ត្រីពុលខ្វះខ្យល់អុកស៊ីសែន

បាចទឹកក្នុងស្រះត្រីពេលឃើញត្រីពុល



# ៧ - ការប្រមូលផល

## ក- ការប្រមូលផលរំលោះ

ក្រោយពីចិញ្ចឹមបានរយៈពេល ៣ខែ ឡើងទៅ អាចចាប់ផ្តើមចាប់ត្រីដែលមានទំហំធំហួបជាបណ្តើរៗ

- ការចាប់ត្រីរំលោះនេះអាចធ្វើឱ្យត្រីដែលនៅសល់ក្នុងស្រះមានការលូតលាស់លឿន
- ការចាប់ត្រីហួបប្រចាំថ្ងៃ អាចប្រើប្រាស់ឧបករណ៍ដូចជា សន្ទូច សំណាញ់ ឬអួន
- តែចំពោះត្រីទីឡាព្យ៉ា បើអ្នកប្រមូលផលរំលោះដោយចាប់ត្រីមេធំៗហួបមុននោះមិនល្អទេ បើសិនជាអ្នកចង់ទុកវាធ្វើត្រីមេពូជ ត្រូវទុកត្រីមេតំបូង ព្រោះកូនរបស់វាធំមិនទាន់បានស្រួលបួលផង វាក៏ចាប់ផ្តើមបង្កើតកូនតទៀត ហើយដែលធ្វើឱ្យត្រីកាន់តែតូចទៅៗ ។



ការស្ទូចត្រីចាប់ហួបប្រចាំថ្ងៃ



ការបង់សំណាញ់ចាប់ត្រីហួបប្រចាំថ្ងៃ

## ខ- ការប្រមូលផលទាំងស្រុង

- ត្រូវធ្វើឡើងនៅពេលត្រីមានតំលៃថ្លៃ ឬ នៅពេលមានតម្រូវការចាំបាច់
- ឬ នៅពេលទឹកស្រះជិតរីងអស់
- ការប្រមូលផលទាំងស្រុង ធ្វើឡើងដោយប្រើម៉ាស៊ីនបូមទឹក ដើម្បីពង្រីងស្រះចាប់ត្រី
- មុនពេលបាច ឬ បូមពង្រីងស្រះ ចាំបាច់ត្រូវត្រៀមឧបករណ៍សំភារៈសំរាប់ប្រស់ត្រីជាមុនសិន។ ក្រោយពេលប្រមូលផលត្រីហើយ អ្នកគួរតែស្តារភក់បាតស្រះ និងជួសជុលស្រះឱ្យបានល្អឱ្យហើយទាន់ពេលដីនៅសើម សំរាប់ការដាក់ចិញ្ចឹមត្រីជាបន្តទៀត។



សកម្មភាពប្រមូលផលត្រីទាំងស្រុង ដើម្បីលក់នឹងសំរាប់ទុកហូប

## II - ការកត់ត្រាចំណាយ និង ចំណូល

ការកត់ត្រាគួរតែកត់ឱ្យបានលំអិតកាន់តែប្រសើរ ព្រោះវាមានសារៈសំខាន់ណាស់ អាចឱ្យយើងដឹងពីការចំណាយ និងចំណូលថវិកា ក្នុងរយៈពេលចិញ្ចឹមត្រី ។

### តារាងចំណាយ

| ល.រ | ថ្ងៃ ខែ ឆ្នាំ | ប្រភេទមុខចំណាយ | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | បូមទឹក ចេញ និងចូលស្រះ | | | | |
| | | ទិញកំបោរ | | | | |
| | | ជី គីមី | | | | |
| | | កូនត្រីពូជ | | | | |
| | | ចំណី | | | | |
| | | ឈ្នួលដឹកជញ្ជូនកូនត្រី | | | | |

### តារាងចំណូល

| ល.រ | ថ្ងៃ ខែ ឆ្នាំ | ប្រភេទមុខចំណូល | ចំនួន | តម្លៃ/ឯកត្តា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | លក់កូនត្រីទីឡាព្យ៉ា | | | | |
| | | ត្រីចាប់ហូប | | | | |
| | | ត្រីឱ្យគេ | | | | |
| | | លក់ត្រីសាច់ | | | | |
| | | ទុកពូជ | | | | |

## III - កត្តាសំខាន់ៗដែលធ្វើឱ្យការចិញ្ចឹមត្រីទទួលបានជោគជ័យ

- ត្រូវជ្រើសរើសទីតាំង និង ជីកស្រះឱ្យបានសមស្រប និងមានពន្លឺថ្ងៃគ្រប់គ្រាន់
- ស្រះត្រូវមានភ្លឺព័ទ្ធជុំវិញ ខ្ពស់ មាំ និង ដាំស្មៅ ដើម្បីកាត់បន្ថយការហូរច្រោះ
- ត្រូវរៀបចំស្រះឱ្យបានត្រឹមត្រូវតាមបច្ចេកទេស មុនពេលដាក់ត្រីចិញ្ចឹម
- ពេលបង្ហូរទឹកចូលស្រះ ត្រូវចងស្បៃនឹងមាត់បំពង់ ដើម្បីការពារត្រីកាច និងសត្វផ្សេងៗស៊ីកូនត្រី
- ត្រូវដាក់កូនត្រីចិញ្ចឹមនៅពេលស្រះមានទឹកគ្រប់គ្រាន់ (ដើមរដូវភ្លៀង)
- កូនត្រីដាក់ចិញ្ចឹមត្រូវមានសុខភាពល្អ ប្រវែងពី ៥- ៦ ស.ម ឬ ៣ ថ្នាំងដៃ
- ចំនួនកូនត្រីចិញ្ចឹមត្រូវដាក់ពី ៣ ទៅ ៤ ក្បាល ក្នុង១ម៉ែត្រការ៉េ
- ដាក់ចិញ្ចឹមត្រីច្រើនប្រភេទ ដើម្បីប្រើអស់លទ្ធភាពចំណីដែលមានក្នុងស្រះ
- ការដាក់ជីជាប្រចាំ ដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ដើម្បីធ្វើឱ្យត្រីធំធាត់ល្អ
- ប្រសិនបើមានចំណី គួរផ្ដល់ចំណីបន្ថែមដែលមានគុណភាពល្អ និងទៀងទាត់ពេលវេលា
- ត្រូវសំអាតរុក្ខជាតិទឹក (ព្រលិត ឈូក កំប្លោក ចកធំ ...) ឱ្យអស់ពីក្នុងស្រះ ។


**ព័ត៌មានបន្ថែមសូមទាក់ទងមកការិយាល័យវារីវប្បកម្ម នៃរដ្ឋបាលជលផល តាមអាសយដ្ឋានដូចខាងក្រោម :-**

ជីឡូត៍លេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ៨៣៥

ទូរស័ព្ទ ទូរសារៈ (៨៥៥) ២៣ ៩៩៦ ៣៨០

**អ៊ីមែល** : smallfish@online.com.kh

## គន្លឹះសំខាន់ៗមួយចំនួនសំរាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

- ការសំអាតស្រះមុនពេលដាក់ត្រីចិញ្ចឹម ជាកត្តាសំខាន់ណាស់ ធ្វើឱ្យការចិញ្ចឹមត្រីរបស់អ្នកបានទទួលជោគជ័យ
- បើមានត្រីផ្ទក់ ឬ ត្រីរស់តែមួយនៅក្នុងស្រះ វានឹងស៊ីកូនត្រីដែលអ្នកដាក់ចិញ្ចឹមអស់ក្នុងរយៈពេលយ៉ាងខ្លី
- ការដាក់ជីជាប្រចាំដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឱ្យត្រីរបស់អ្នកធំធាត់ល្អ
- ពន្លឺថ្ងៃជាកត្តាសំខាន់មួយធ្វើអោយចំណីធម្មជាតិ ឬ ប្លង់តុងកើតក្នុងស្រះបានល្អក្រោយពេលដាក់ជី
- ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយភ្ជាប់ទៅស្រែ ជាវិធីមួយដ៏ល្អ ជួយអោយត្រីរបស់អ្នកធំធាត់ឆាប់រហ័ស
- ហើយអ្នកអាចបន្ថយការចំណាយលើការផ្តល់ចំណីទៀតផង ។

## រូបមន្តសំខាន់ៗដែលអ្នកគួរចងចាំ សំរាប់ការចិញ្ចឹមត្រី

ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ = ប្រវែងបណ្តោយស្រះជាម៉ែត្រ x ប្រវែងទទឹងស្រះជាម៉ែត្រ

ឧទាហរណ៍ : ស្រះមានប្រវែងបណ្តោយ ១៥ម និង ទទឹង ១០ម ។ ផ្ទៃក្រឡាស្រះ = ១៥ម x ១០ម = ១៥០ ម$^{២}$

បរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ x $\frac{\text{បរិមាណកំបោរប្រើក្នុងមួយរយម៉ែត្រការ៉េ}}{១០០}$

ឧទាហរណ៍ : ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើកំបោរ ១០គក្រ ក្នុង ១០០ម$^{២}$ ។ បរិមាណកំបោរប្រើប្រាស់ក្នុងស្រះ = ១៥០ x $\frac{១០}{១០០}$ = ១៥ គក្រ

ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ x ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុង ១ម$^{២}$

ឧទាហរណ៍ : ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ដាក់ត្រីចិញ្ចឹម ៣ក្បាល ក្នុង១ម$^{២}$ ។ ចំនួនកូនត្រីដាក់ចិញ្ចឹម = ១៥០ x ៣ = ៤៥០ ក្បាល

បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ផ្ទៃក្រឡាស្រះជាម៉ែត្រការ៉េ x $\frac{\text{បរិមាណជីអ៊ុយរ៉េប្រើក្នុងមួយរយម៉ែត្រការ៉េ}}{១០០}$

ឧទាហរណ៍ : ស្រះមានផ្ទៃក្រឡា ១៥០ម$^{២}$ ចង់ប្រើជីអ៊ុយរ៉េ ៤ខាំ ក្នុង ១០០ម$^{២}$ ។ បរិមាណជីអ៊ុយរ៉េប្រើប្រាស់ក្នុងស្រះ = ១៥០ x $\frac{៤}{១០០}$ = ៦ ខាំ